ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ចាម

សំណុំរឿងរដ្ឋប្បវេណី
លេខ ៤៦៨
ចុះថ្ងៃទី០៨.១១.២០១៩
សាលក្រមរដ្ឋប្បវេណី
លេខ ១៣៩ "ង"
ចុះថ្ងៃទី១៦.០៧.២០២០

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកំពង់ចាម

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០ លើសំណុំរឿងរដ្ឋប្បវេណីលេខ ៤៦៨ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩។

**ចៅក្រមជំនុំជម្រះ**

**លោកស្រី [redacted] ជាចៅក្រមសាលាដំបូងខេត្តកំពង់ចាម**

**ក្រឡាបញ្ជីសវនាការ**

**លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ចាម**

-ដើមចោទឈ្មោះ [redacted] វេន ភេទស្រី អាយុ ៦៥ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ អាសយដ្ឋាន [redacted] ប្តីឈ្មោះ [redacted] មាង (រស់) មានកូន ០២នាក់ ឪពុកឈ្មោះ [redacted] ធី (ស្លាប់) ម្តាយឈ្មោះ [redacted] មឿន (រស់)។

-អ្នកតំណាងដោយអាណត្តិ គ្មាន ។

-ចុងចម្លើយឈ្មោះ [redacted] មាង ភេទប្រុស អាយុ ៦៦ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ អាសយដ្ឋាន [redacted] ប្រពន្ធឈ្មោះ [redacted] វេន (រស់) មានកូន ០២នាក់ ឪពុកឈ្មោះ [redacted] ម៉ូវ (ស្លាប់) ម្តាយឈ្មោះ [redacted] ឃិន (រស់)។

-អ្នកតំណាងដោយអាណត្តិលោកស្រីមេធាវី [redacted]។

**អង្គហេតុ និងចំណុចវិវាទ**

ដើមចោទឈ្មោះ [redacted] វេន បានរៀបការជាមួយចុងចម្លើយឈ្មោះ [redacted] សុខខេង នៅក្នុងជំនាន់ប៉ុលពត តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ទេ។ តាំងពីបានគ្នាជាប្តីប្រពន្ធមកគូភាគីមានកូន ០២នាក់ និងមានទ្រព្យសម្បត្តិរួមផងដែរ ហើយដើមចោទ និងចុងចម្លើយរស់នៅលែងយល់ចិត្តគ្នា មិនចុះសម្រុងគ្នា និងរស់នៅបែកពីគ្នាយូរហើយ ទើបជាហេតុធ្វើឱ្យដើមចោទអស់មនោសញ្ចេតនាពីចុងចម្លើយ។

**១.ការទាមទាររបស់ដើមចោទ**

-សុំឈប់នៅជាអនីតិសង្វាសពីចុងចម្លើយឈ្មោះ [redacted] មាង។

-សុំបែងចែកផ្ទះ និងដីលំនៅឋាន ដែលជាទ្រព្យសម្បត្តិរួម។

Scanned with CamScanner

## ២.ការអះអាងរបស់គូភាគី

ដើមចោទឈ្មោះ [redacted] រ៉េន បានធ្វើសេចក្តីថ្លែងការណ៍នៅនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ថា: នាងខ្ញុំនៅតែប្តឹងសុំឱ្យតុលាការចេញសាលក្រម សុំឈប់រស់នៅជាអនីតិសង្វាសពីចុងចម្លើយឈ្មោះ [redacted] **មាង** ដោយសំអាងហេតុថា: នាងខ្ញុំ និងចុងចម្លើយបានយកគ្នាជាប្តីប្រពន្ធ នៅក្នុងជំនាន់ប៉ុលពត តែរហូតមកដល់ពេលនេះពុំទាន់បានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ។ ការរួមរស់នៅជាប្តីប្រពន្ធកន្លងមកដោយសារចុងចម្លើយជឿតាមឪពុកម្តាយ និងបងប្អូន ចុងចម្លើយបានវាយធ្វើបាបនាងខ្ញុំដូចគោដូចក្របីជាច្រើនឆ្នាំមកហើយ ទើបនាងខ្ញុំទ្រាំរស់នៅជាមួយគ្នាមិនកើត ហើយសព្វថ្ងៃនេះ នាងខ្ញុំ និងចុងចម្លើយបានរស់នៅបែកគ្នាជាច្រើនឆ្នាំមកហើយ។ តាំងពីរស់នៅបែកពីគ្នាមក ចុងចម្លើយមិនដែលឱ្យនាងខ្ញុំចូលផ្ទះទេ ដោយចុងចម្លើយចោទប្រកាន់ថាកូនឈ្មោះ [redacted] **សុខអ៊ាង** នាងខ្ញុំបានខូចជាមួយអ្នកផ្សេង។ នាងខ្ញុំ និងចុងចម្លើយមានកូនពីរនាក់ កូនទី១.ឈ្មោះ [redacted] **សុខទាង** ភេទស្រី និងកូនទី២.ឈ្មោះ [redacted] **សុខអ៊ាង** ភេទស្រី។ ទ្រព្យសម្បត្តិរួមមាន: ផ្ទះឈើទំហំ ៨ម៉ែត្រ គុណ ៨ម៉ែត្រ សង់លើដីលំនៅឋានទំហំ ២៥ម៉ែត្រ គុណ ៤២ម៉ែត្រ នាងខ្ញុំសុំឱ្យតុលាការសម្រេចបែងចែកជាពីរចំណែកស្មើគ្នា។

ចុងចម្លើយឈ្មោះ [redacted] **មាង** បានធ្វើសេចក្តីថ្លែងការណ៍នៅនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ថា: បើសិនជាដើមចោទសុំឈប់រស់នៅជាអនីតិសង្វាសពីខ្ញុំបាទនោះ ខ្ញុំបាទក៏ព្រមព្រៀងដែរ ពីព្រោះថា ខ្ញុំបាទ និងដើមចោទបានរស់នៅបែកពីគ្នាយូរឆ្នាំហើយ។ ខ្ញុំបាទ និងដើមចោទ ពិតបានរៀបការតាំងពីសម័យប៉ុលពត ហើយពុំទាន់បានចុះសំបុត្រអាពាហ៍ពិពាហ៍មែន។ មូលហេតុនៃការឈប់រស់នៅជាមួយគ្នានេះ គឺមិនពិតដូចការអះអាងរបស់ដើមចោទនោះទេ ការអះអាងរបស់ដើមចោទសុទ្ធតែជាពាក្យមូលបង្កាច់ទាំងអស់ កន្លងមកបើខ្ញុំបាទវាយធ្វើបាបចុងចម្លើយដូចពាក្យគាត់ថាមែននោះ តើខ្ញុំបាទរស់នៅក្នុងភូមិស្រុកបានសុខដែរទេ? ខ្ញុំបាទបានយកម្តាយមករស់នៅជាមួយខ្ញុំមែន តែអត់បានវាយធ្វើបាបដូចការចោទប្រកាន់របស់ដើមចោទទេ។ ខ្ញុំបាទ និងដើមចោទបានរស់នៅបែកពីគ្នាអស់រយៈពេល១៣ឆ្នាំ៦ខែហើយ រហូតមកដល់ពេលនេះ។ ទ្រព្យសម្បត្តិរួមមាន: ផ្ទះឈើទំហំ ៨ម៉ែត្រ គុណ ៨ម៉ែត្រ សង់លើដីលំនៅឋានទំហំ ២៥ម៉ែត្រ គុណ ៤២ម៉ែត្រ ហើយកាលពីដើមឡើយជាទ្រព្យសម្បត្តិរួមមែន ប៉ុន្តែកាលពីឆ្នាំ២០១២ ផ្ទះ និងដីលំនៅឋាននេះ ខ្ញុំបាទ និងដើមចោទ ព្រមទាំងកូនទាំងពីរនាក់ បានឯកភាពគ្នាលក់ឱ្យទៅកូនទី១ឈ្មោះ [redacted] សុខទាង រួចហើយ ដោយកូនទី១បានប្រគល់ប្រាក់ដែលជាចំណែកនៃផ្ទះ និងដី ឱ្យទៅម្តាយតាមរយៈកូនប្អូនឈ្មោះ [redacted] សុខអ៊ាង និងប្តីរបស់គេរួចហើយ គឺតាំងពីឆ្នាំ២០១៤ ចំនួន ២.៨០០ដុល្លា-អាមេរិក មានប្អូនស្រីខ្ញុំ កូនខ្ញុំឈ្មោះ [redacted] សុខទាង និងខ្ញុំបាទ បានចូលរួមដឹងឮ តែពុំមានអាជ្ញាធរដឹងឮទេ រីឯលិខិតស្នាមក៏អត់បានធ្វើដែរ។ ផ្ទះ និងដីលំនៅឋាននេះ សព្វថ្ងៃកូនស្រីឈ្មោះ [redacted] សុខទាង ជាអ្នកកាន់កាប់ និងគ្រប់គ្រង ហើយខ្ញុំបាទបានរស់នៅជាមួយកូនស្រីដែរ ព្រោះថាកូនឈ្មោះ [redacted] សុខទាង ជាអ្នកមើលថែទាំខ្ញុំ។

ដើមចោទឈ្មោះ [redacted] **រ៉េន** បានធ្វើសេចក្តីថ្លែងការណ៍បន្ថែមថា: ផ្ទះ និងដីដែលជាទ្រព្យសម្បត្តិរួមនេះ នាងខ្ញុំអត់លក់ទេ។ ផ្ទះ និងដីនេះ នាងខ្ញុំ និងចុងចម្លើយបានទិញពីឪពុកម្តាយរបស់ខ្ញុំ។

Scanned with CamScanner

ចុងចម្លើយឈ្មោះ [redacted] ម៉ាង បានធ្វើសេចក្ដីថ្លែងការណ៍តបបន្ថែមថា: ដីភូមិដែលជាកេររបស់ដើមចោទដំបូងឡើយមានក្បាល១២ម៉ែត្រ ក្រោយមកក៏ចេះតែទិញថែម១បីម្ចាស់ទៀត ទើបបានក្បាល២៥ម៉ែត្រ សរុបទាំងដីកេររបស់ដើមចោទ តែកន្លងផ្ទះ និងដីភូមិនេះ បានឯកភាពគ្នាលក់ឱ្យទៅកូនឈ្មោះ [redacted] សុខទាង រួចហើយ គឺតាំងពីឆ្នាំ២០១២ម្លេះ។ ក្រោយពីឯកភាពគ្នាលក់ផ្ទះ និងដីនេះឱ្យទៅកូនទី១ហើយ នៅឆ្នាំ២០១២ កូនទី១.ឈ្មោះ [redacted] សុខទាង ក៏បានទៅធ្វើលិខិតស្នើសុំបញ្ជាក់អចលនទ្រព្យចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២ ដើម្បីយកផ្ទះ និងដីនេះទៅដាក់ធានាខ្ចីលុយចំនួន ១០.០០០ដុល្លាអាមេរិក ឱ្យប្អូនឈ្មោះ [redacted] សុខអ៊ាង ផងដែរ ហើយការធានានេះ មិនមែនកូនឈ្មោះ [redacted] សុខទាង ជាអ្នកសងទេ គឺកូនឈ្មោះ [redacted] សុខអ៊ាង ជាអ្នកសងគេទេ។

ដើមចោទឈ្មោះ [redacted] រេន បានធ្វើសេចក្ដីថ្លែងការណ៍បន្ថែមថា: លិខិតស្នើសុំបញ្ជាក់អចលនទ្រព្យចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២ ពីមេភូមិមេឃុំនោះ នាងខ្ញុំអត់បានដឹងទេ គឺចុងចម្លើយ និងកូន លួចធ្វើទេ។ លុយចំនួន ១០.០០០ដុល្លាអាមេរិកនេះ កូនស្រីពៅពិតជាបានទទួលយកមែន ហើយការយកផ្ទះ និងដីទៅដាក់បញ្ចាំនៅធនាគារនាងខ្ញុំព្រមឱ្យយកទៅដាក់បញ្ចាំមែន។

កូនទី១ឈ្មោះ [redacted] **សុខទាង** បានឆ្លើយថា: កាលពីឆ្នាំ២០១២ នាងខ្ញុំពិតជាបានធានាលុយចំនួន ១០.០០០ដុល្លាអាមេរិក ឱ្យប្អូនឈ្មោះ [redacted] សុខអ៊ាង យកទៅទិញផ្ទះមែន។ ការទិញលក់ផ្ទះ និងដីពីឪពុកម្ដាយ នាងខ្ញុំអត់បានធ្វើលិខិតស្នាមទេ ដោយនិយាយគ្នាផ្ទាល់មាត់ ប៉ុន្តែលុយថ្លៃផ្ទះចំនួន ២.៨០០ដុល្លា-អាមេរិក នាងខ្ញុំបានប្រគល់ឱ្យទៅម្ដាយតាមរយៈប្អូនស្រីឈ្មោះ [redacted] សុខអ៊ាង និងប្ដីឈ្មោះ សីហា គឺឱ្យជាលុយដុល្លាទាំងអស់ នាងខ្ញុំបានប្រគល់ឱ្យនៅលើផ្ទះដោយផ្ទាល់ដៃ មានមីងរបស់ខ្ញុំឈ្មោះ [redacted] ឃីម គាត់នៅអង្គុយមើលការប្រគល់ទទួល និងរាប់លុយរហូត។ លុយ១០.០០០ដុល្លាអាមេរិកនេះ នាងខ្ញុំគ្រាន់តែជាអ្នកធានាទេ ហើយប្អូនជាអ្នកសង។

កូនទី២ឈ្មោះ [redacted] **សុខអ៊ាង** បានឆ្លើយថា: លុយថ្លៃផ្ទះ និងដី ចំនួន ២.៨០០ដុល្លាអាមេរិក នាងខ្ញុំបានទទួលមែន តែលុយនោះជាលុយលក់ដីស្រែទេ។ កន្លងមកនាងខ្ញុំពិតជាបានឱ្យបងស្រីឈ្មោះ [redacted] សុខទាង ធានាលុយឱ្យនាងខ្ញុំចំនួន ១០.០០០ដុល្លាអាមេរិកមែន ហើយទ្រព្យដែលដាក់ធានាក្នុងការខ្ចីលុយនេះ គឺផ្ទះ និងដីរបស់ឪពុកម្ដាយ មិនមែនជាផ្ទះ និងដីរបស់បងស្រីទេ។

សាក្សីឈ្មោះ [redacted] **ឃីម** បានឆ្លើយថា: នាងខ្ញុំត្រូវជាប្អូនបង្កើតរបស់ចុងចម្លើយ។ ការលើកឡើងរបស់ដើមចោទ គឺជាការមួលបង្កាច់នាងខ្ញុំ និងបងនាងខ្ញុំ។ ពេលក្មួយឈ្មោះ [redacted] សុខទាង ប្រគល់លុយឱ្យទៅដើមចោទ នាងខ្ញុំបានឃើញដោយផ្ទាល់ ដោយសារនាងខ្ញុំនៅផ្ទះជាមួយក្មួយ។ នៅឆ្នាំ២០១២ ដើមចោទ និងចុងចម្លើយបានឯកភាពគ្នាថា ព្រមប្រគល់ផ្ទះ និងដី ឱ្យទៅកូនបងឈ្មោះ [redacted] សុខទាង ហើយការប្រគល់លុយថ្លៃផ្ទះ និងដីនេះ នាងខ្ញុំក៏បានចូលរួមដែរ ប្រគល់នៅលើផ្ទះ កាលណោះខ្ញុំនៅលើផ្ទះនោះដែរ ដោយប្រគល់ឱ្យជាលុយដុល្លាទាំងអស់ នាងខ្ញុំអត់បានជួយរាប់ទេ គ្រាន់តែអង្គុយមើល ហើយអ្នកដែលមកទទួលយកលុយ គឺឈ្មោះ [redacted] សុខអ៊ាង និងប្ដី ឯម្ដាយអត់បានមកទេ ជាប់នៅមើលចៅ។

Scanned with CamScanner

សាក្សីឈ្មោះ [redacted] ពីម បានឆ្លើយថាៈ ខ្ញុំបាទជាមេភូមិបន្ទាយ តាំងពីអើយរហូតមកដល់សព្វថ្ងៃនេះ។ ផ្ទះ និងដី ដែលដើមចោទប្តឹងសុំបែងចែកនេះ គឺជាដីរបស់ឈ្មោះ [redacted] វេន និងឈ្មោះ [redacted] មាង ហើយកាលពីឆ្នាំ២០១២ ខ្ញុំបាទពិតជាបានចុះហត្ថលេខាបញ្ជាក់ឱ្យឈ្មោះ [redacted] សុខទាង និងប្តីមែន។ បានជាខ្ញុំបាទបញ្ជាក់ឱ្យកូនដែលមិនមែនជាម្ចាស់ទ្រព្យនោះ កាលណោះខ្ញុំបាទអត់បានសួរនាំទេ ដោយអាងថាជាគ្រួសារតែមួយ។ ចំពោះការលក់ផ្ទះ និងដីភូមិ ខ្ញុំបាទអត់បានដឹងទេ។

សាក្សីឈ្មោះ [redacted] រិន បានឆ្លើយថាៈ ខ្ញុំបាទជាមេឃុំបារាយណ៍ និងធ្លាប់បានដោះស្រាយឱ្យភាគីទាំងពីរនាក់នេះផងដែរ។ កន្លងមកពេលខ្ញុំដោះស្រាយ ខ្ញុំតែងតែសម្រួលថាឱ្យចែកទ្រព្យសម្បត្តិរួមឱ្យទៅប្រពន្ធរហូត ពីព្រោះថាផ្ទះ និងដី ជាទ្រព្យសម្បត្តិរួមរបស់គាត់ទាំងពីរនាក់។ ការលក់ផ្ទះ និងដីនេះ ឱ្យទៅកូនឈ្មោះ [redacted] សុខទាង ខ្ញុំបាទអត់បានដឹងទេ។ ចំពោះការបញ្ជាក់លើម្ចាស់ទ្រព្យទាល់តែជាម្ចាស់ទ្រព្យពិតប្រាកដ ទើបភូមិឃុំធ្វើលិខិតបញ្ជាក់ឱ្យ។

លោកស្រីមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] មាង បានធ្វើសេចក្តីសន្និដ្ឋានថាៈ កូនក្តីនាងខ្ញុំឈ្មោះ [redacted] មាង និងឈ្មោះ [redacted] វេន បានរៀបការជាមួយគ្នាក្នុងអំឡុងឆ្នាំ១៩៧៦ ហើយការរស់នៅជាមួយគ្នាកន្លងមកពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ តែមានកូនពីរនាក់ កូនទី១.ឈ្មោះ [redacted] សុខទាង និងកូនទី២.ឈ្មោះ [redacted] សុខអ៊ាង។ ការរស់នៅជាប្តីប្រពន្ធកន្លងមកមានភាពរកាំរកូសខ្លះដែរ តែអាចរស់នៅជាមួយគ្នាបាន។ លុះដល់ឆ្នាំ២០០៧ ឈ្មោះ [redacted] វេន គាត់ក៏បានទៅរស់នៅជាមួយកូនឈ្មោះ [redacted] សុខអ៊ាង ដើម្បីជួយមើលចៅនៅភ្នំពេញ ក្នុងមួយឆ្នាំគាត់មកផ្ទះម្តងឬពីរដងទេ ដោយទុកឱ្យប្តីនៅផ្ទះតែម្នាក់ឯង បានកូនស្រីឈ្មោះ [redacted] សុខទាង ជាអ្នកមើលថែ។ ក្រោយមកនៅឆ្នាំ២០១២ កូនស្រីឈ្មោះ [redacted] សុខអ៊ាង មានការខ្វះខាតលុយបើកកន្លែងរកស៊ីនៅភ្នំពេញ ក៏បានឱ្យម្តាយមកលក់ផ្ទះ និងដីភូមិ ដែលជាចំណែករបស់ម្តាយ(ទ្រព្យសម្បត្តិរួមប្តីប្រពន្ធ [redacted] មាង និង [redacted] វេន) ឱ្យទៅកូនស្រីបងឈ្មោះ [redacted] សុខទាង ក្នុងតំលៃ ២.៨០០ដុល្លាអាមេរិក ពេលនោះក៏មានការយល់ព្រមពីឈ្មោះ [redacted] វេន និងកូនក្តីខ្ញុំ តែពេលនោះកូនឈ្មោះ [redacted] សុខទាង ពុំទាន់បានប្រគល់លុយឱ្យទៅម្តាយភ្លាមទេ។ នៅក្នុងឆ្នាំ២០១២នោះដែរឈ្មោះ [redacted] សុខទាង និងប្តីឈ្មោះ [redacted] ឈឿន ក៏បានធ្វើលិខិតស្នើសុំបញ្ជាក់អចលនទ្រព្យទៅអាជ្ញាធរភូមិឃុំ ហើយអាជ្ញាធរភូមិឃុំក៏បានបញ្ជាក់ឱ្យ។ បន្ទាប់មកទៀតដល់ឆ្នាំ២០១៤ ឈ្មោះ [redacted] សុខអ៊ាង បានលក់របស់របរ រួចក៏ហៅម្តាយឈ្មោះ [redacted] វេន ឱ្យមកទទួលយកលុយដែលជាចំណែកនៃផ្ទះ និងដីភូមិ តែម្តាយអត់បានមកទេ ដោយឱ្យកូនឈ្មោះ [redacted] សុខអ៊ាង និងប្តី មកយកជំនួស គឺលុយចំនួន ២.៨០០ដុល្លាអាមេរិក។ ការទិញលក់ផ្ទះ និងដី ពុំបានធ្វើកិច្ចសន្យាទេ ដោយអាងថា ឪពុកម្តាយ និងកូន ហើយពុំដែលមានរឿងរ៉ាវនឹងគ្នាទេ ម្យ៉ាងទៀតដោយមានការយល់ព្រមទាំងអស់គ្នា។ ដោយផ្អែកតាមចម្លើយដើមចោទ ចម្លើយចុង-ចម្លើយ ចម្លើយកូនស្រីទាំងពីរនាក់ ចម្លើយសាក្សី និងឯកសារពាក់ព័ន្ធនៅក្នុងសំណុំរឿង ក្នុងនាមនាងខ្ញុំជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] មាង នាងខ្ញុំសំណូមពរសុំឱ្យតុលាការសម្រេចច្រានចោលការទាមទាររបស់ដើមចោទទាំងមូល។

Scanned with CamScanner

**៣.ចំណុចវិវាទ**

-ដើមចោទស្នើសុំបែងចែកទ្រព្យសម្បត្តិរួមមាន: ផ្ទះ និងដីលំនៅឋាន តែចុងចម្លើយមិនព្រមបែងចែកទេ។

**សំអាងហេតុ**

-ពាក្យបណ្តឹងចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ដើមចោទឈ្មោះ [redacted] វេន មានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ តែផ្ទុយនឹងគតិច្បាប់។

-ដើមចោទ និងចុងចម្លើយ ជាប្តីប្រពន្ធដែលពុំមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ឡើយ គឺរស់នៅជាអនីតិសង្វាស។

-បានឃើញ លិខិតស្នើសុំបញ្ជាក់អចលនទ្រព្យរបស់ឈ្មោះ [redacted] សុទាង និងប្តីឈ្មោះ [redacted] ឈឿន ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២ (ថតចម្លង)។

**-តាមលទ្ធផលនៃសេចក្តីថ្លែងការណ៍នៅនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឃើញថា:**

-ដើមចោទ និងចុងចម្លើយ ជាប្តីប្រពន្ធដែលពុំមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ឡើយ។ ជាក់ស្តែងដើមចោទ និងចុងចម្លើយ បានរស់នៅបែកពីគ្នារួចហើយ គប្បីតុលាការមិនពិចារណាដល់ចំណុចនេះទេ។

-ដើមចោទអះអាងថាទ្រព្យសម្បត្តិរួមមាន: ផ្ទះឈើប្រក់ក្បឿង ជញ្ជាំងបន្ទំឫស្សី ២ខ្នង ទំហំ ៨ម៉ែត្រ គុណ ៨ម៉ែត្រ សង់លើដីលំនៅឋានទំហំ ២៥ម៉ែត្រ គុណ ៤២ម៉ែត្រ ស្ថិតនៅភូមិបន្ទាយ ឃុំបារាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ដើមចោទសុំបែងចែកជាពីរចំណែកស្មើគ្នា តែចុងចម្លើយអះអាងថា ផ្ទះ និងដីលំនៅឋាន ដែលដើមចោទប្តឹងសុំបែងចែកដូចខាងលើនេះ កាលពីឆ្នាំ២០១២ ខ្លួន និងដើមចោទបានព្រមព្រៀងលក់ឱ្យទៅកូនឈ្មោះ [redacted] សុខទាង ព្រមទាំងបានទទួលយកនូវចំណែកនៃផ្ទះ និងដី ជាប្រាក់ចំនួន ២.៨០០ដុល្លា-អាមេរិករួចហើយដែរ ហើយកូនឈ្មោះ [redacted] សុខអ៊ាង ក៏បានទទួលស្គាល់ថា ខ្លួនពិតជាបានទទួលលុយចំនួន ២.៨០០ដុល្លាអាមេរិក ពីបងស្រីឈ្មោះ [redacted] សុខទាង ពិតប្រាកដមែន ម្យ៉ាងទៀតតាមលិខិតស្នើសុំបញ្ជាក់អចលនទ្រព្យរបស់ឈ្មោះ [redacted] សុខទាង និងប្តីឈ្មោះ [redacted] ឈឿន ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២ បានបញ្ជាក់ថា: ម្ចាស់អចលនទ្រព្យលើដីលំនៅឋានទំហំ ២៥ម៉ែត្រ គុណ ៤២ម៉ែត្រ ស្ថិតនៅភូមិបន្ទាយ ឃុំបារាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម គឺជាឈ្មោះ [redacted] សុខទាង និងប្តីឈ្មោះ [redacted] ឈឿន ដូច្នេះគប្បីតុលាការពិចារណា និងសម្រេចច្រានចោលការទាមទាររបស់ដើមចោទ។

-ដើមចោទឈ្មោះ [redacted] វេន គឺជាអ្នកដាក់ពាក្យបណ្តឹង ហេតុនេះ ប្រាក់ប្រដាប់ក្តីគប្បីជាបន្ទុករបស់ដើមចោទ។

**សេចក្តីសម្រេចបញ្ចប់**

១-ច្រានចោលការទាមទាររបស់ដើមចោទឈ្មោះ [redacted] វេន។

២-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទឈ្មោះ [redacted] វេន។

Scanned with CamScanner

Civil 468/08.11.2019

៣-សាលក្រមនេះ ប្រកាសជាសាធារណៈ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០ ចំពោះមុខដើមចោទឈ្មោះ [redacted] វេន ចំពោះចុងចម្លើយឈ្មោះ [redacted] មាង និងមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ។

-ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា**

[redacted]

---

" បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម "

ថ្ងៃព្រហស្បតិ៍ ១១រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

កំពង់ចាម ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]